# ឆែប

**A1, A3 & A4i**



**ខេត្ត** : ព្រះវិហារ

**ស្រុក** : ឆែប និង ជាំក្សាន្ត

**ផ្ទៃដី ( ហិកតា)** : ២៤៣.៦៦១

**រយៈកំពស់ ( ម៉ែត្រ)** : ៣៥ ដល់ ៧៦៧

**កូអរដោនេចំណុចកណ្តាល** : ១៤$^{0}$០៤'ជ ១០៥$^{0}$ ៣០'ក

## ការពិពណ៌នាទីកន្លែង

តំបន់ IBA នេះ ស្ថិតនៅក្នុងវាលរាបភាគខាងជើងនៃប្រទេសកម្ពុជាត្រង់តំបន់ព្រៃអភិរក្សធនធានសេនេទិច និង សត្វព្រៃ "ព្រះវិហារ" ក្នុងស្រុកឆែប និង ជាំក្សាន្ត ។ រុក្ខជាតិនៅក្នុងតំបន់នេះមានលក្ខណៈទីជំរកស្មុគស្មាញដោយសារគុណភាពដី ដែលស្ថិតនៅជិតទឹក និង តាមទីតាំងភូមិសាស្ត្រ ។ ប្រភេទដីសម្បូរដោយខ្សាច់ និង ខ្សោះជីជាតិទ្រទ្រង់នូវប្រភេទព្រៃរបោះដែលគ្របដណ្តប់លើសលប់ដោយឈើពីរទៅបីប្រភេទប៉ុណ្ណោះ ។ ប្រភេទដីល្បាប់មានជីជាតិ ជានិច្ចកាលស្ថិតនៅជិតមាត់ទឹកទ្រទ្រង់ព្រៃឈើច្រើនប្រភេទគ្រប់ដណ្តប់លើសលប់ដោយដើមឈើធំខ្ពស់ៗ ដែលមានគំរបព្រៃផ្តល់ម្លប់បានល្អលើស្រទាប់ស្មៅខាងក្រោម ។ វាលស្មៅលិចទឹកតាមរដូវកាលធំល្វឹងល្វើយនៅក្នុងព្រៃរបោះនៃតំបន់នេះ គឺជាវាលស្មៅល្អមានតែមួយកន្លែងប៉ុណ្ណោះដែលសេសសល់ក្នុងតំបន់អាស៊ី ។ នៅប៉ែកខាងជើង តំបន់នេះជាប់ជាមួយនឹងបណ្តាតំបន់ដែលមានប្រភេទទីជំរកធម្មជាតិស្រដៀងគ្នាក្នុងប្រទេសឡាវ ។

តំបន់នេះទ្រទ្រង់ពពួកសត្វស្លាបច្រើនប្រភេទរស់ក្នុងប្រភេទព្រៃរបោះនៃតំបន់កណ្តាលក្នុងតំបន់ឥណ្ឌូចិន ហើយក៏បានទ្រទ្រង់ផងដែរនូវប្រភេទទទួលរងការគំរាមកំហែង និង ជិតរងគ្រោះក្នុងពិភពលោក រួមមានក្ងោក ទាព្រៃស្លាបស ក្រៀល ត្មាតផេះ ត្មាតត្នោត ត្មាតភ្លើង ត្រដក់ធំ ត្រដក់តូច និង អង្កត់ខ្មៅ ។ ជាការកត់សំគាល់បំផុតនោះគឺ តំបន់នេះបានទ្រទ្រង់ចំនួនរបស់ប្រភេទត្រយ៉ងយក្សចំនួនច្រើនក្បាលបំផុតក្នុងពិភពលោក លើសពីនេះទៀត វាក៏បានទ្រទ្រង់ផងដែរនូវប្រភេទចាបដូនតាវាលស្រែ ។

## ប្រភេទសត្វស្លាបសំខាន់ៗ

| ឈ្មោះខ្មែរ | ឈ្មោះអង់គ្លេស | ឈ្មោះវិទ្យាសាស្ត្រ | លក្ខណៈវិនិច្ឆ័យIBA |
|---|---|---|---|
| ក្ងោក | Green Peafowl | *Pavo muticus* | A1 |
| កេងកងធំ | Great Hornbill | *Buceros bicornis* | A1 |
| ក្រៀល | Sarus Crane | *Grus antigone* | A1 |
| ចាបដូនតាវាលស្រែ | Manchurian Reed Warbler | *Acrocephalus tangorum* | A1 |
| ចាបពូកទ្រូងលឿង | Asian Golden Weaver | *Ploceus hypoxanthus* | A1 |
| ត្មាតត្នោត | Long-billed Vulture | *Gyps indicus* | A1 |
| ត្មាតផេះ | White-rumped Vulture | *Gyps bengalensis* | A1 |
| ត្មាតភ្លើង | Red-headed Vulture | *Sarcogyps calvus* | A1 |

| | | | | |
|---|---|---|---|---|
| ត្រដក់តូច | Lesser Adjutant | *Leptoptilos javanicus* | A1 | A4i |
| ត្រដក់ធំ | Greater Adjutant | *Leptoptilos dubius* | A1 | |
| ត្រយ៉ងយក្ស | Giant Ibis | *Pseudibis gigantea* | A1 | A4i |
| ទាព្រៃស្លាបស | White-winged Duck | *Cairina scutulata* | A1 | |
| ស្ទាំងស្លាបស្រួចចុងខ្នងស | White-rumped Falcon | *Polihierax insignis* | A1 | |
| អង្គត់ខ្មៅ | Black-necked Stork | *Ephippiorhynchus* asiaticus | A1 | A4i |
| អកត្រីក្បាលប្រផេះ | Grey-headed Fish Eagle | *Ichthyophaga ichthyaetus* | A1 | |
| អកខ្មៅជីសើម | Greater Spotted Eagle | *Aquila clanga* | A1 | |

**ប្រភេទសត្វប្រមូលផ្តុំក្នុងតំបន់មួយជាក់លាក់**

មានសត្វស្លាបមួយប្រភេទរស់នៅក្នុងប្រភេទព្រៃតំបន់ភ្នំខ្ពស់ៗ ប្រាំប្រភេទរស់នៅក្នុងប្រភេទព្រៃស្រោង និង ១៤ប្រភេទរស់នៅក្នុងប្រភេទព្រៃរបោះ (សូមមើលតារាងឧបសម្ព័ន្ធ៤) ។

**ប្រភេទពានរជាតិទទួលរងការគំរាមកំហែងពិភពលោក**

រញ្ជិប្រផេះ ស្វាត្រោស និង ស្វាក្តាម ។

**ដំរី និង ពពួកក្រចកជំពាមទទួលរងការគំរាមកំហែងពិភពលោក**

ដំរី រមាំង ខ្ទីង និង ទន្សោង ។

**ប្រភេទអណ្តើក កន្ធាយ និង ក្រពើទទួលរងការគំរាមកំហែងពិភពលោក**

អណ្តើកបិទមុខស្នូកខ្មៅ អណ្តើកសោមញី អណ្តើកក្របីក្បាលលឿង អណ្តើកព្រិច និង កន្ធាយអាស៊ី ។

**ការគំរាមកំហែងលើជីវៈចំរុះ**

ការប្រមាញ់គឺកើតឡើងក្នុងកំរិតទាប ជាសំខាន់សម្រាប់ការបំពេញបន្ថែមក្នុងជីវភាពរស់នៅ ហើយទោះជាគេគិតថាការបរបាញ់មានការកើនឡើង ក៏បច្ចុប្បន្នការគំរាមកំហែងនេះមិនជះឥទ្ធិពលចំពោះសត្វស្លាបទឹកធំៗឡើយ ។ ប៉ុន្តែអាចកើតឡើងដោយសារការប្រមូលយកពងកូនពីសំបុក ជាពិសេសក្រៀល ។ ប្រជាពលរដ្ឋមូលដ្ឋានដែលរស់នៅជិតព្រំដែនឡាវបានរាយការណ៍ឱ្យដឹងពីការប្រើប្រាស់ថ្នាំពុលក្នុងត្រពាំង និង តាមអូរនានាដើម្បីចាប់ត្រី ដែលសកម្មភាពនេះអាចធ្វើឱ្យសត្វស្លាបទឹកងាប់ផងដែរ ។ ការនេសាទដោយប្រើប្រាស់គ្រឿងផ្ទុះ តាមរបាយការណ៍មានការកើនឡើងនៅតាមត្រពាំងនានា ។ ការគំរាមកំហែងមួយទៀតលើជីវៈចំរុះ គឺការកាប់ព្រៃឈើខុសច្បាប់នៅក្នុងតំបន់ព្រៃពាក់កណ្តាលស្រោង ជាពិសេសនៅតាមផ្លូវទឹក ។ ការគំរាមកំហែងចំបងនាពេលអនាគតលើជីវៈចំរុះក្នុងតំបន់រួមមានជនអន្តោប្រវេសន៍ (តាមរយៈការអភិវឌ្ឍន៍ផ្លូវថ្នល់តាមខេត្ត) ការពង្រីកដីកសិកម្ម និង ការកើនឡើងនៃការបរបាញ់ដោយសារមានមនុស្សចំណូលថ្មី ។

**អនុសាសន៍**

វិធានការបង្ក្រាបការបរបាញ់ និង ការធ្វើពាណិជ្ជកម្មសត្វព្រៃគួរតែអនុវត្តនៅក្នុងតំបន់ទាំងមូល ដោយបង្កើតឡើងប្រព័ន្ធល្បាតនៅក្នុងតំបន់ព្រៃអភិរក្សខេត្តព្រះវិហារ ។

ការដៅលើផែនទីនូវរាល់តំបន់ដីសើម និង តំបន់ពងកូនសំខាន់ៗរបស់សត្វព្រៃ និង កន្លែងដែលមានមនុស្សរស់នៅក្នុងតំបន់ព្រៃការពារខេត្តព្រះវិហារគួរតែអនុវត្ត ។ ការងារនេះនឹងតម្រូវឱ្យមានការសិក្សាស្រាវជ្រាវបន្ថែម ហើយយកទិន្នន័យទាំងនេះមកប្រើប្រាស់សម្រាប់ការធ្វើផែនការអភិរក្ស ។

មានការទទួលស្គាល់លើផែនការអភិវឌ្ឍន៏ថ្នាក់ជាតិ និង ថ្នាក់ខេត្តពីស្ថាប័នពាក់ព័ន្ធនានា ។

ការអភិរក្សសត្វស្លាបទឹកធំៗគួរតែបញ្ចូលក្នុងសកម្មភាពការងារបញ្ចុប្បន្នដោយធ្វើការជាមួយសហគមន៏មូលដ្ឋានដើម្បីអភិរក្សសត្វរមាំង ។

បង្កើតឡើងនូវកិច្ចព្រមព្រៀងសហគមន៏លើការប្រើប្រាស់តំបន់ដីសើមសំខាន់ៗ ឆ្កែប្រមាញ់ ការប្រមូលយកពងកូន និង ការប្រើប្រាស់ថ្នាំពុល ។ កម្មវិធីសន្តិសុខស្បៀងសម្រាប់ភូមិសំខាន់ៗគួរតែធ្វើឡើង ដើម្បីជំរុញឱ្យមានការត្រួតពិនិត្យ និង ជួយទ្រទ្រង់ ដល់ការអភិរក្សដោយផ្អែកលើសហគមន៏ ។

ការហូរចូលជនអន្តោប្រវេសន៏ ការតាំងទីលំនៅខុសច្បាប់ និង ទន្ទ្រានយកដីនៅក្នុងតំបន់សំខាន់ៗក្នុងតំបន់ព្រៃអភិរក្សខេត្តព្រះវិហារគួរតែទប់ស្កាត់ ។

## ឯកសារយោង

Barzen, J. (2001) Waterbirds and wetlands of northern Cambodia. *Bugle* 27(4): 1-2.

Barzen, J. (2002) Waterbirds and wetlands of northern Cambodia. *Cambodia Bird News* 9:36-38.

Davidson, P. (2001) A further twelve new species for Cambodia. *Cambodia Bird News* 7: 26-35

Davidson, P., Poole, C. M. and Walston, J. (2001) Cambodia's northern plains: heartland of the Giant Ibis. *World Birdwatch* 23 (4): 15-19.

Goes, F. (2001) L'Ibis Géant, un oiseau légendaire et misanthrope. *Cambodia Bird News* 7: 2-6. (In French.)

Goes, F. and Davidson, P. eds. (2001) Recent sightings. *Cambodia Bird News* 7: 38-45.

Goes, F. and Davidson, P. eds. (2002) Recent sightings. *Cambodia Bird News* 9: 47-59.

Prum Sovanna (2001) *Mammal list from Preah Vihear province*. Unpublished report to the Wildlife Conservation Society Cambodia Program.

Tan Setha (2001) *Bird checklist from Preah Vihear province*. Unpublished report to the Wildlife Conservation Society Cambodia Program.